# បង្កើនល្បឿន ការកាត់បន្ថយភាពក្រីក្រ

*ថ្វីបើសំរេចបានកំនើនសេដ្ឋកិច្ចដ៏ខ្ពស់នៅទសវត្សរ៍មុន ប្រទេសកម្ពុជាដែលមានអត្រាភាពក្រីក្រដល់ទៅ ៣៥% នៅតែស្ថិតក្នុងចំណោមប្រទេសមានអត្រាក្រីក្រខ្ពស់ជាងគេនៅក្នុងតំបន់ ។ ប៉ុន្តែឥឡូវនេះ ដល់ពេលត្រូវពន្លឿនការកាត់បន្ថយភាពក្រីក្រហើយ ។ នៅក្នុងសន្និសីទចក្ខុវិស័យ រៀបចំដោយ វបសអ នាខែកុម្ភៈ ឆ្នាំ២០០៧ ក្រុមជំនាញការមួយដែលរួមមាន លោកស្រី* **Nisha Agrawal** *លោក ច័ន្ទ សុផល និងលោក ឈិត សំអាត បានពិភាក្សាពីវិធីកំណត់គោលដៅ និងពន្លឿនការកាត់បន្ថយភាពក្រីក្រ ។**

## បទបង្ហាញរបស់លោកស្រី Nisha Agrawal – ធនាគារពិភពលោក

នៅឆ្នាំ១៩៩៤-២០០៤ កម្ពុជាបានទទួលជោគជ័យគួរឱ្យកត់សំគាល់ ។ កម្ពុជាសំរេចបានសន្តិភាព និងស្ថិរភាព បន្ទាប់ពីមានសង្គ្រាម និងភាពវឹកវរដ៏រ៉ាំរ៉ៃមក ។ ក្នុងអំឡុងពេលនោះ មានកំណើនសេដ្ឋកិច្ចដ៏ខ្ពស់ប្រហែល ៧% ក្នុងមួយឆ្នាំ ។ ការកាត់បន្ថយភាពក្រីក្របានជឿនលឿនទៅមុខគួរសម ដោយអត្រាក្រីក្របានថយចុះពី ៤៧% មកត្រឹម ៣៥% រឺក្នុងមួយឆ្នាំៗនាទសវត្សរ៍នោះ មានប្រជាជនប្រមាណ ១% ថែមទៀត បានចាកផុតពីភាពក្រីក្រ ។ ម្យ៉ាងទៀត សូចនាករសង្គមបានប្រសើរឡើងជាទូទៅ ពិសេសក្នុងវិស័យសុខាភិបាល និងអប់រំ ។

ទន្ទឹមគ្នានឹងជោគជ័យខាងលើ វិសមភាពក៏កើនឡើងដែរ ។ វិសមភាពរវាងអ្នកមាន និងអ្នកក្រ បានកើនឡើងយ៉ាងគំហុកនៅទសវត្សរ៍ចុងក្រោយ ។ កំរិតជីវភាពរស់នៅរបស់អ្នកមានជាងគេ ២០% បានកើន ៥ដង លឿនជាងកំរិតជីវភាពរបស់អ្នកក្រជាងគេ ២០% ដោយមានកំនើន ៤៥% ធៀបនឹង ៨% ។ ម្យ៉ាងទៀត មានគំលាតកើនរវាងតំបន់នានា ហើយភាពក្រីក្រកាន់តែធ្ងន់ធ្ងរនៅជនបទ ។ ចំនួនប្រជាជនក្រីក្រ បានថយចុះយ៉ាងលឿននៅភ្នំពេញ និងនៅតំបន់មាត់សមុទ្រ បើធៀបនឹងតំបន់ផ្សេងទៀត ។ ធៀបនឹងប្រទេសជិតខាង វិសមភាពនៅកម្ពុជាមានកំរិតខ្ពស់គឺ ០,៤២ នៅឆ្នាំ២០០៤ រីឯនៅវៀតណាម មានត្រឹមតែ ០,៣៥ នៅឆ្នាំ២០០២ ឥណ្ឌូនេស៊ី មាន ០,៣៤ នៅឆ្នាំ២០០០ ។ល។

ចំពោះអ្នកនយោបាយ វិសមភាពក៏ជាបញ្ហាសំខាន់ដែរ ។ នៅក្នុងសុន្ទរកថានៅថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០៧ សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន បានប្រកាសថា នៅកម្ពុជាយើងត្រូវប្រឈមមុខនឹងបញ្ហាច្រើនណាស់ ដែលអាចកាត់បន្ថយស្ថិរភាពនយោបាយ និងសង្គម ។ បញ្ហាទាំងនេះ រួមមានកំណើនទំនាស់ដីធ្លី សំពាធ និងការរុករានរបស់មនុស្សទៅលើធនធានធម្មជាតិ មូលដ្ឋានតូចចង្អៀតនៃកំណើនសេដ្ឋកិច្ច និងកំណើនវិសមភាព ដូច្នេះត្រូវមានការបែងចែកឡើងវិញនូវផ្លែផ្កានៃកំណើនសេដ្ឋកិច្ច ដើម្បីបង្កើនអត្ថប្រយោជន៍ដល់អ្នកក្រ ។ ហានិភ័យ និងបញ្ហាប្រឈមទាំងនេះ គួរបំប្លែងឱ្យទៅជាឱកាសល្អវិញ ។

### *នរណាជាអ្នកក្រជាងគេ ២០%?*

អ្នកក្រជាងគេ ២០% កំពុងស្ថិតនៅខាងក្រោមខ្សែបន្ទាត់ក្រីក្រ ហើយភាគច្រើនរស់នៅតាមវាលទំនាបក្នុងតំបន់ជនបទ តាមដងទន្លេសាប តាមតំបន់ភ្នំ និងខ្ពង់រាប ត្រូវពឹងផ្អែកយ៉ាងខ្លាំងលើកសិកម្មនិងធនធានទ្រព្យរួម ដូច្នេះងាយរងគ្រោះណាស់ ពីព្រោះវត្ថុមាន និងការទទួលបានធនធានទាំងនោះ បានថយចុះ ។ ពួកគេ ក៏មានលទ្ធភាពតិចតួចដើម្បីបានប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធ និងសេវាដ៏ចាំបាច់នានា ។

### *សកម្មភាពបីសំខាន់ៗ ដើម្បីទទួលបានវិបុលភាពរួម*

សកម្មភាពដ៏សំខាន់បំផុតមួយដើម្បីទទួលបានវិបុលភាពរួម គឺការបង្កើនលទ្ធភាពមានដីប្រើប្រាស់ និងសន្តិសុខក្នុងការកាន់កាប់ដីធ្លី សំរាប់ប្រជាជនក្រីក្រនៅជនបទ ។ រដ្ឋាភិបាលកម្ពុជា បានដាក់អនុវត្តរបបសម្បទានដីបំរើសេដ្ឋកិច្ច (ELCs) ដោយពីឆ្នាំ១៩៩២-២០០៦ បានផ្តល់ដីបែបនេះក្រោមលក្ខខណ្ឌជួលរយៈពេល៧០ឆ្នាំ នៅក្នុង១៦ខេត្ត ទៅឱ្យ ៩៦ក្រុមហ៊ុនឯកជន ដែលក្នុងនោះមាន ៥៧ក្រុមហ៊ុន នៅមានដំណើរការ (មិនទាន់លុបចោល) លើដីសម្បទានប្រហែល ១លានហិកតា ។ ដោយឡែក មាន ១៤សម្បទាន ដែលនីមួយៗមានផ្ទៃដីលើសកំរិតកំណត់ ១០.០០០ហិកតា ហើយដែលត្រូវធ្វើការត្រួតពិនិត្យជាពិសេសឡើងវិញ ។ ប៉ុន្តែមកទល់សព្វថ្ងៃ មិនទាន់មានការត្រួតពិនិត្យណាមួយនៅឡើយទេ ។ ទោះបីមានហេតុផលខាងគោលនយោបាយថា ELCs ជាការចាំបាច់សំរាប់ជំរុញផលិតភាព កំណើន និងការប្រកួតប្រជែង ក៏បច្ចុប្បន្នមានតែ ១០ របបសម្បទានដីបំរើសេដ្ឋកិច្ចដែលកំពុងដំណើរការជាក់ស្តែង ។ ចំពោះសម្បទានក្រៅពីនោះ គេទុកដីឱ្យនៅទំនេរចោលដោយរង់ចាំកេងយកចំណេញពីការឡើងថ្លៃ ។ ដូច្នេះមានសំនួរចោទឡើងថា តើនេះជាវិធីប្រសើរបំផុតក្នុងការប្រើប្រាស់ដីនៅកម្ពុជារឺយ៉ាងណា?

នៅពេលដែលដីកសិកម្មធំៗ នៅទំនេរក្រោមរូបភាពជារបបសម្បទានដីបំរើសេដ្ឋកិច្ច (ELCs) គេឃើញមានតំរូវការខ្លាំងខាងសេដ្ឋកិច្ចនូវដីធ្លីសំរាប់អ្នកមានដីកសិកម្មតូចៗ និងសំរាប់សម្បទានដីសង្គមកិច្ច (SLCs) ។ គ្រួសារនៅជនបទ ២០% ជាអ្នកគ្មានដី និងមានគ្រួសារកាន់តែច្រើនបានក្លាយទៅជាអ្នកស្ទើរគ្មានដី រឺមានដីតូចៗ ។ យោងតាមអនុក្រឹត្យស្តីពីសម្បទានដីសង្គមកិច្ចឆ្នាំ២០០៣ រដ្ឋាភិបាលមានគោលនយោបាយលុបចោលសម្បទានដីខាងសេដ្ឋកិច្ចដែលមិនដំណើរការ ហើយផ្ទេរដីទៅឱ្យគ្រួសារគ្មានដី ។ ការបែងចែកដីសាជាថ្មីនេះ មានហេតុផលច្បាស់លាស់ពាក់ព័ន្ធនឹងផលិតភាពសេដ្ឋកិច្ច កំណើន និងការកាត់បន្ថយភាពក្រីក្រ ។ ប៉ុន្តែការអនុវត្តន៏គោលនយោបាយសម្បទានដីសង្គមកិច្ចយឺតយ៉ាវខ្លាំងណាស់ ដូច្នេះត្រូវតែមានការពន្លឿនឡើង ។

សកម្មភាពសំខាន់មួយទៀត គឺការធ្វើចំរុះកម្មប្រភពកំណើនសព្វថ្ងៃ និងពង្រឹងចំណងទាក់ទងរវាងកំនើន និងការកាត់បន្ថយភាពក្រីក្រ ។ កំនើនសេដ្ឋកិច្ចនាបច្ចុប្បន្ន មានមូលដ្ឋានតូចណាស់ ដោយពឹងផ្អែកលើតែវិស័យកាត់ដេរ និងទេសចរណ៏ ។ វិស័យកាត់ដេរផ្តល់ការងារដល់កម្មករជាង ៣០០.០០០នាក់ នៅចុងឆ្នាំ២០០៦ និង ៨០% នៃទំនិញនាំចេញ ។ ការពឹងផ្អែកខ្លាំងចំពោះវិស័យតែមួយនាំឱ្យមានមូលដ្ឋានកំណើនតូចចង្អៀត ដែលងាយរងគ្រោះដោយសារការប៉ះទង្គិចពីខាងក្រៅ ។ វិស័យកាត់ដេរតែមួយ ក៏មិនគ្រប់គ្រាន់ដែរ ដោយសារជារៀងរាល់ឆ្នាំ មានប្រជាជន ២៥០.០០០នាក់ ឈានចូលទៅក្នុងទីផ្សារការងារ ។ ដូច្នេះត្រូវធ្វើចំរុះកម្មវិស័យផលិតដើម្បីបង្កើតការងារឱ្យបានច្រើនថែមទៀត ។

---

* លោកស្រី Nisha Agrawal ជាអ្នកគ្រប់គ្រងប្រចាំនៅកម្ពុជា នៃធនាគារពិភពលោក ។ លោក ច័ន្ទ សុផល ជាប្រធានស្រាវជ្រាវជាន់ខ្ពស់ផ្នែកសេដ្ឋកិច្ច ពាណិជ្ជកម្ម និងសហប្រតិបត្តិការក្នុងតំបន់ នៃវិទ្យាស្ថាន CDRI និងលោក ឈិត សំអាត ជានាយកអង្គការ NGO Forum នៅកម្ពុជា ។

ចំណងទាក់ទងទៅខាងដើមខ្សែនៃវិស័យទេសចរណ៍ ត្រូវមានជាចាំបាច់ដើម្បីធានាឱ្យកំណើនទេសចរណ៍ រួមចំណែកកាត់បន្ថយភាពក្រីក្រ ។ ក្នុង៥ឆ្នាំចុងក្រោយ វិស័យទេសចរណ៍មានកំណើនមធ្យម ២៦%/ឆ្នាំ ។ ភ្ញៀវទេសចរភាគច្រើន ទៅទស្សនាខេត្តសៀមរាប ។ ប៉ុន្តែសៀមរាបនៅតែស្ថិតក្នុងចំណោមខេត្តក្រីក្របំផុតនៅកម្ពុជា ។ ទេសចរណ៍មិនផ្តល់អត្ថប្រយោជន៍ច្រើនដល់អ្នកក្រទេ បើសិនគ្មានយុទ្ធសាស្ត្រជាក់លាក់ដែលផ្តោតលើផលប៉ះពាល់នៃទេសចរណ៍ ជាជាងលើចំនួនអ្នកទេសចរ ។

ជាចុងបញ្ចប់ ត្រូវមានការផ្តោតសេវា និងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗទៅបំរើក្រុមខ្សត់ខ្សោយ និងបង្កើនការចូលរួមពីក្រុមទាំងនេះនៅក្នុងការពិភាក្សាពីបញ្ហាអភិវឌ្ឍន៍ ។ ទោះជាចំនួនសុទ្ធនៃការចុះឈ្មោះចូលរៀននៅបឋមសិក្សាបានកើនឡើងសំរាប់គ្រប់ក្រុមប្រាក់ចំណូលក្តី ប៉ុន្តែអ្នកក្របំផុតនៅតែទទួលបានសេវាឯទៀតៗ តិចតួចនៅឡើយ ។ ឧ. អ្នកក្រជាងគេ ៤០% ស្ទើរតែមិនបានទទួលសេវាខាងទឹកស្អាត និងអនាម័យសោះ ។ ដូច្នេះត្រូវតែខំផ្តោតការប្រឹងប្រែងដើម្បីឱ្យសេវាភាគច្រើនទៀត បានទៅដល់អ្នកក្រីក្របំផុតដែរ ។

## បទបង្ហាញរបស់លោក ច័ន្ទ សុផល-វិទ្យាស្ថាន CDRI-វបសអ

ថ្វីបើយើងពេញចិត្តចំពោះកំណើនជាទូទៅនៃការអភិវឌ្ឍន៍ ប៉ុន្តែយើងមានការព្រួយបារម្ភយ៉ាងខ្លាំង ដោយសារមានបញ្ហាមួយចំនួនបានផុសឡើង និងប្រហែលវិវត្តកាន់តែធ្ងន់ធ្ងរ បើសិនការអភិវឌ្ឍន៍នៅតំបន់ជនបទមួយចំនួន មិនបានបង្កើនល្បឿនទាន់ពេលនោះទេ ។ បញ្ហាទាំងនោះ រួមមានកំណើនទំនាស់លើការប្រើប្រាស់ទឹករវាងកសិករនិងម្ចាស់ឡូតិ៍នេសាទ ការរុករាននិងការប្រែក្លាយជាទ្រង់ទ្រាយធំនូវដីព្រៃនិងព្រៃលិចទឹក កំណើនភាពងាយរងគ្រោះរបស់អ្នកក្រ ជាពិសេសស្ត្រីក្នុងគ្រួសារក្រីក្របំផុត ហើយនិងការប្រឈមនឹងគ្រោះថ្នាក់នៃការលួចប្លន់និងការប្រើប្រាស់គ្រឿងញៀន ក្នុងចំណោមយុវជន ។

ការសិក្សាច្រើនឆ្នាំក្នុង៩ភូមិ នៅទូទាំងប្រទេសបង្ហាញថា កំណើនការកាត់បន្ថយភាពក្រីក្រ មិនបានដូចគ្នាគ្រប់កន្លែងទេ ។ សហគមន៍ខ្លះបានរីកចំរើនយ៉ាងខ្លាំងក្នុងរយៈពេលបីឆ្នាំ ខ្លះទៀតគ្មានការប្រែប្រួលសោះ ហើយខ្លះទៀតបានធ្លាក់ក្រជាងមុនថែមទៀត ។ ដូចគ្នាដែរ គ្រួសារខ្លះមានជីវភាពប្រសើរឡើង រឺបានចាកផុតពីភាពក្រីក្រ ប៉ុន្តែខ្លះទៀតមានជីវភាពចុះខ្សោយ រឺធ្លាក់ចូលក្នុងភាពក្រីក្រ ។ កត្តាដែលបង្កចលនាបែបនេះ មានសារៈសំខាន់ណាស់សំរាប់ការពិភាក្សាខាងគោលនយោបាយ ។

ហេតុផលជំរុញឱ្យសហគមន៍មានជីវភាពប្រសើរឡើង មានជាសំខាន់ (១) កំណើនចំណូលពីកសិកម្ម ដោយសារការកែលំអបច្ចេកទេសកសិកម្ម ប្រព័ន្ធធារាសាស្ត្រ និងទីផ្សារ (២) កំណើនលទ្ធភាពទទួលបានឱកាសល្អនៅខាងក្រៅ ដោយសារការកសាងផ្លូវថ្នល់ និង (៣) ការពង្រីកអាជីវកម្មខ្នាតតូចដែលទទួលបានការគាំទ្រមួយចំណែកពីការរីកដុះដាលឥណទានខ្នាតតូច ។

មានបុព្វហេតុសំខាន់មួយដែលធ្វើឱ្យសហគមន៍និងគ្រួសារ កាន់តែខ្សត់ខ្សោយនិងនៅតែក្រីក្រខ្លាំង ។ នៅទសវត្សរ៍កន្លងទៅ គេឃើញមានការខូចខាតព្រៃឈើយ៉ាងលឿន ដោយសារបរាជ័យក្នុងការដាក់អនុវត្តន៍ច្បាប់ ។ ទោះបីជាស្ថិតិជាតិលើបរិមាណត្រីចាប់បាន គ្មានបង្ហាញសញ្ញានៃការថយចុះក្តី ប៉ុន្តែធនធានជលផលកាន់តែប្រមូលបានដោយអ្នកមាន ជាពិសេសអ្នកនៅខាងក្រៅសហគមន៍នេសាទ ។ ជាលទ្ធផល អ្នកក្របែរជាត្រូវប្រឈមនឹងការថយចុះស្តុកត្រី ។ម្យ៉ាងទៀត ត្រីចាប់បានក៏កាន់តែតូចទៅៗ រីឯត្រីធំៗវាកាន់តែក្រឡើងៗ ។

ការបារម្ភធំមួយទៀត គឺសហគមន៍រស់នៅក្បែរព្រៃឈើ និងបឹងទន្លេសាប ហាក់ដូចជាកាន់តែក្រទៅៗ ។ ធនធានរួមដែលខូចខាតស្រាប់នាបច្ចុប្បន្នប្រហែលមិនអាចទ្រទ្រង់ជីវភាពអ្នកក្រីក្របានច្រើនគ្រួសារឡើយ ហើយយើងកំពុងពិចារណាថា តើមានជំរើសអ្វីផ្សេងទៀតសំរាប់ឱ្យគ្រួសារទាំងនោះរស់តទៅមុខ ។ នាពេលថ្មីៗ គ្រួសារមួយចំនួនដែលពឹងផ្អែកលើធនធានព្រៃឈើត្រូវពួកម្ចាស់ដីថ្មីៗជួលឱ្យកាប់ឆ្ការព្រៃ និងធ្វើរបងព័ទ្ធជុំវិញចំការពួកគេក្នុងគោលបំណងរង់ចាំលក់យកចំណេញ ។ ដូច្នេះនៅពេលសកម្មភាពទិញដីស្ងាត់អស់ទៅ គ្រួសារទាំងនោះត្រូវតែស្វែងរករបរចិញ្ចឹមជីវិតផ្សេងទៀតហើយ ។

វិស័យនាំមុខគេពីរ គឺឧស្សាហកម្មកាត់ដេរ និងទេសចរណ៍ ហាក់ដូចមិនបានជួយទ្រទ្រង់ច្រើនទេដល់ការកាត់បន្ថយភាពក្រីក្រ ពីព្រោះវាមានចំណងទាក់ទងទៅដើមខ្សែតិចពេក ។ យើងចង់ឱ្យវិស័យទាំងពីរលូតលាស់ថែមទៀតក៏ពិតមែន ប៉ុន្តែមានការយល់ស្របជាទូទៅថា ការអភិវឌ្ឍន៍កសិកម្មឱ្យទៅជាក្បាលម៉ាស៊ីនទីបីនៃកំណើន គឺជាវិធីសក្តិសិទ្ធិបំផុតសំរាប់កាត់បន្ថយភាពក្រីក្រ ។ ឥឡូវនេះ ដល់ពេលធ្វើសកម្មភាពហើយ ។

ការអភិវឌ្ឍន៍កសិកម្ម តំរូវឱ្យមានការបែងចែកធនធានកាន់តែច្រើនថែមទៀតទៅកសាងប្រព័ន្ធស្រោចស្រព និងធ្វើការផ្សព្វផ្សាយនិងស្រាវជ្រាវខាងកសិកម្ម ។ ការកែលំអលើការចុះបញ្ជីដីធ្លី ការគ្រប់គ្រងដី ការកែច្នៃកសិផល ការរកទីផ្សារសំរាប់ផលិតផលកសិកម្ម និងឥណទានមានការប្រាក់ទាប សុទ្ធសឹងជាកត្តាសំខាន់បំផុត ។ រហូតមកដល់ពេលនេះ ចំណាយទៅលើកសិកម្ម និងប្រព័ន្ធស្រោចស្រព វាមានចំនួនតិចតួចពេក ។ យោងតាមថវិកាជាតិផ្សព្វផ្សាយដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចំណាយរដ្ឋាភិបាលលើកសិកម្មនៅឆ្នាំ២០០៥ មានតែ ១៣លានដុល្លារ នៃចំណាយសរុបប្រហែល ៨០០លានដុល្លារ ។ ចំណាយខាងកសិកម្មរបស់អ្នកផ្តល់ជំនួយ មាន ៣៥លានដុល្លារ នៃ ៥០០លានដុល្លារ ។ ចំណាយរបស់រដ្ឋាភិបាល និងអ្នកផ្តល់ជំនួយទៅលើប្រព័ន្ធស្រោចស្រពមានសរុប ១៣លានដុល្លារ នៅឆ្នាំ២០០៥ គឺនៅដដែលក្នុងពីរ-បីឆ្នាំ ចុងក្រោយ ។

ប្រទេសកម្ពុជាមានសក្តានុពលខ្ពស់ ក្នុងការអភិវឌ្ឍន៍កសិ-ឧស្សាហកម្ម ។ រហូតមកដល់សព្វថ្ងៃ គេតែងមើលរំលងវិស័យនេះ ។ ផលដំណាំវត្ថុធាតុដើមភាគច្រើនតែងនាំចេញទៅប្រទេសជិតខាងដើម្បីកែច្នៃ និងនាំចេញបន្ត ។ កម្ពុជាមិនត្រឹមតែបាត់បង់ឱកាសទទួលបានតំលៃបន្ថែមលើផលិតផលនោះទេ ប៉ុន្តែការនាំចេញទាំងនោះថែមទាំងមិនផ្លូវការ និងមានកំហិតជាច្រើន ។ ដោយសារនៅចិនមានកំនើនតំរូវការផលិតផលកសិកម្ម ដូចជាដំឡូងមី និងសណ្តែកសៀងជាដើម ដូច្នេះគេមានឱកាសរកចំណេញបានច្រើនណាស់ពីវិនិយោគក្នុងកសិ-ឧស្សាហកម្ម ប៉ុន្តែត្រូវមានការកាត់បន្ថយថែមទៀតជាបន្ទាន់នូវបន្ទុកចំណាយក្នុងការធ្វើអាជីវកម្ម និងពាណិជ្ជកម្មនៅកម្ពុជា ។ អ្វីដែលរដ្ឋាភិបាលអាចធ្វើបាន គឺកាត់បន្ថយចំណាយលើការដឹកជញ្ជូន និងការយកកំរៃផ្សេងៗនៅព្រំដែន ។

កម្ពុជា នៅតែជាប្រទេសមានចំណាយខ្ពស់ខាងដឹកជញ្ជូន និងថាមពល ។ យោងតាមការសិក្សាប្រៀបធៀបនៅឆ្នាំ២០០៤ ដោយបណ្តាវិទ្យាស្ថានស្រាវជ្រាវនៅក្នុងបណ្តាញវិភាគអភិវឌ្ឍន៍ (DAN) ដែលនាំមុខដោយវិទ្យាស្ថានវបសអ-CDRI ការដឹកជញ្ជូនផលដំណាំ ១តោន ជាពោត សណ្តែកសៀង រឺដំឡូងមី ក្នុងចំងាយផ្លូវ ១០០គ.ម ត្រូវចំណាយអស់ ១០-១២ដុល្លារ នៅកម្ពុជា ប៉ុន្តែអស់ត្រឹម ៤-៥ដុល្លារនៅវៀតណាម និង ២,៥ដុល្លារនៅថៃ ។ ចំណាយកាន់តែអស់ច្រើន និងស្មុគស្មាញថែមទៀត ចំពោះការនាំចេញផលិតផលកសិកម្មឆ្លងកាត់ព្រំដែន ។ ឧ. សំរាប់ពោត ១០តោន កំរៃសរុប គឺ ៥០-៨០ដុល្លារ សំរាប់ឯច្រកព្រំដែនខ្លះនៅតាមព្រំដែនថៃ ។ ពាណិជ្ជករត្រូវឆ្លងកាត់អាជ្ញាធរមួយចំនួន ដូចជា នគរបាលអន្តរជាតិ គយ កាំកុងត្រូល នគរបាលសេដ្ឋកិច្ច ទាហាន អាវុធហត្ថ អាជ្ញាធរព្រំដែន និងអ្នកសំរបសំរួលព្រំដែនទាំងសងខាង ។

អាជ្ញាធរខ្លះមានការិយាល័យផ្សេងគ្នា សំរាប់ថ្នាក់ជាតិ ថ្នាក់ខេត្ត និងថ្នាក់ស្រុក ។

កម្ពុជាអាចធ្វើសកម្មភាពបានច្រើនថែមទៀត ដើម្បីប្រមូលផលប្រយោជន៍ពីកំណើនឱកាសបានចូលទៅក្នុងទីផ្សារតំបន់ និងទីផ្សារពិភពលោក ។ រឿងនេះអាចធ្វើទៅបាន ដោយបង្កើនផលិតកម្ម និងវិនិយោគនៅក្នុងការកែច្នៃកសិផល និងដោយកាត់បន្ថយចំណាយម៉ាឃីតទីង ។ កម្ពុជាអាចប្រើប្រាស់ដីបានប្រសើរជាងនេះ ដើម្បីជួយអ្នកក្រ ទាំងនៅតំបន់ចាស់និងថ្មី ដែលមានការកាប់បំផ្លាញព្រៃឈើ ដោយកែលំអប្រព័ន្ធស្រោចស្រពផ្តល់ឱកាសឱ្យចូលពាក់ព័ន្ធទីផ្សារ និងធ្វើការបែងចែកដីដោយមានសមធម៌ ។ ក្នុងនេះដែរ សម្បទានដីសេដ្ឋកិច្ចដែលមិនដំណើរការ គួរតែពិចារណាឡើងវិញឱ្យបានម៉ត់ចត់ ។ ការទិញលក់កេងយកចំណេញ និងការទន្ទ្រានយកដី ដែលកើនឡើងយ៉ាងលឿន គួរគ្រប់គ្រងឱ្យបានដោយប្រមូលយកពន្ធលើដីធំៗ ។ វិធានការនេះ នឹងជួយបង្កើនផលិតកម្មផលដំណាំសំរាប់បំពេញតំរូវការក្នុងតំបន់ដែលកំពុងវិវត្តយ៉ាងលឿននេះ ។ ឧ. នៅឆ្នាំ២០០៥ ថៃ និងវៀតណាមបាននាំចេញដំឡូងមី ៥០០លានដុល្លារ និង ៥០លានដុល្លារ ទៅចិន ។ សំរាប់កម្ពុជាគេប៉ាន់ស្មានថា បាននាំចេញដំឡូងមីប្រហែល ៥លានដុល្លារប៉ុណ្ណោះក្នុងឆ្នាំនោះ ។ ការសិក្សារបស់យើងបង្ហាញថា កម្ពុជាអាចបង្កើនផលិតកម្មជាច្រើនដងទៀត បើសិនចេះប្រើប្រាស់ដីឱ្យមានប្រសិទ្ធភាព ។ ដោយហេតុថា ដំណាំជាច្រើនអ្នកក្រអាចដាំដុះបាន ដូច្នេះកំណើនផលិតកម្មការកែច្នៃ និង ការនាំចេញ នឹងជួយកាត់បន្ថយភាពក្រីក្រដោយផ្ទាល់ ។

ដើម្បីឱ្យផលិតកម្ម ការកែច្នៃ និងម៉ាឃីទីងផលដំណាំទទួលបានចំណេញត្រូវមានសកម្មភាពសំខាន់ៗដូចតទៅ:

- ផ្តល់គ្រឿងលើកទឹកចិត្តដល់វិស័យឯកជន ដើម្បីបង្កើនវិនិយោគក្នុងឧស្សាហកម្មកែច្នៃកសិផល
- ប្រើប្រាស់ដីដោយមានប្រសិទ្ធភាព និងកាត់បន្ថយចំណាយប្រតិបត្តិការរបស់អាជីវកម្ម (រួមទាំង ចំណាយដឹកជញ្ជូន និងកំរៃនៅតាមព្រំដែន) ដើម្បីជួយឱ្យវិនិយោគមានផលចំណេញ
- ផ្តល់គ្រឿងលើកទឹកចិត្តដល់មន្ត្រីរាជការ ឱ្យជួយសំរួលពិតៗដល់កិច្ចប្រឹងប្រែងរបស់វិស័យឯកជន មិនអោយរាំងស្ទះដល់ការងាររបស់គេទេ ។

### បទបង្ហាញរបស់លោក ឈិត សំអាត-អគ្គនាយក NGO Forum

កម្ពុជាមានការអភិវឌ្ឍន៍យ៉ាងខ្លាំងក្នុងរយៈ១០ឆ្នាំចុងក្រោយ មានអត្រាកំណើនសេដ្ឋកិច្ចខ្ពស់ជាប់រហូត ហើយបច្ចុប្បន្នមានសន្តិភាពពេញលេញល្អ ។ អត្រាភាពក្រីក្រ បានថយចុះប្រហែល ៨% ។ ជាមួយគ្នានេះ វិសមភាពរវាងអ្នកមាន និងអ្នកក្រ បានកើនឡើង ធ្វើឱ្យកម្ពុជាធ្លាក់ចូលទៅក្នុងចំណោមប្រទេសដែលមានគំលាតខ្ពស់ជាងគេរវាងអ្នកមាន និងអ្នកក្រ ។ ភាពក្រីក្រនៅតែមានអត្រាខ្ពស់ដល់ ៣៥% ។ អត្រាមរណៈកុមារ បានកាត់បន្ថយមកត្រឹម ៦៥នាក់/១.០០០កំណើតរស់ រីឯអត្រាមរណៈមាតុភាពនៅតែខ្ពស់ ប្រហែល ៤៧២នាក់/១០០.០០០ កំណើតរស់ ។[1]

មានសំនួរផុសឡើងថា តើអន្តរាគមន៍អភិវឌ្ឍន៍ត្រូវផ្តោតយ៉ាងដូចម្តេចដើម្បីកាត់បន្ថយភាពក្រីក្របានលឿន មានសមភាពកាន់តែប្រសើរ និងធ្វើឱ្យអភិវឌ្ឍន៍មានចីរភាពពិតៗ? ក្នុងនេះយើងត្រូវពិចារណាលើ ១) គំរូល្អបំផុតនៃការអភិវឌ្ឍន៍សេដ្ឋកិច្ច ដើម្បីសំរេចបានការអភិវឌ្ឍន៍មានចីរភាព និងសមភាព និង ២) សកម្មភាពនានាដែលផ្តោតជាសំខាន់លើអ្នកក្រីក្រ និងជនងាយរងគ្រោះ ។

អង្គការមិនមែនរដ្ឋាភិបាល (NGOs) ភាគច្រើន កំពុងធ្វើការជាមួយក្រុមអ្នកក្រីក្រ និងជនងាយរងគ្រោះ ដូចជា អ្នកក្រគ្មានដី ភូមិជនបទដាច់ស្រយាលប្រជាជនដើម សហគមន៍ពឹងផ្អែកលើព្រៃឈើនិងការនេសាទ ជនពិការជនរងគ្រោះដោយសារការជួញដូរនិងអំពើហិង្សាក្នុងគ្រួសារ ជនរងគ្រោះដោយជំងឺអេដស៍ សហគមន៍ក្រីក្រនៅតំបន់ទីក្រុង និងជនរងគ្រោះដោយសារការរំលោភបំពានសិទ្ធិមនុស្ស ។ NGOs បានមើលឃើញជារឿយៗពីបែបបទដែលកំណើននិងការអភិវឌ្ឍន៍សេដ្ឋកិច្ច បានរំលងចោលពួកអ្នកក្រីក្រ និងជនងាយរងគ្រោះ ហើយពេលខ្លះវាធ្វើឱ្យពួកគេរឹតតែយ៉ាប់យ៉ឺនថែមទៀត ។

ដោយមូលហេតុដូចខាងលើ NGOs ជារឿយៗបានទិតៀនដល់ទស្សនៈថាកម្ពុជាចាំបាច់ត្រូវទាក់ទាញវិនិយោគគ្រប់ប្រភេទ និងស្វែងរកកំណើនសេដ្ឋកិច្ចគ្រប់បែបយ៉ាង ។ តាមពិត វិនិយោគប្រភេទខ្លះអាចបំផ្លិចបំផ្លាញដល់ជីវភាពរស់នៅរបស់សហគមន៍ក្រីក្រ និងបង្វែរធនធានចេញពីអ្នកក្រទៅឱ្យអ្នកមាននិងគ្រួសារមធ្យមទៅវិញ ។

យើងមិនបាច់រៀបរាប់លំអិតពេកទេ ពីការព្រួយបារម្ភចំពោះផលប៉ះពាល់នៃសម្បទានដីកសិកម្មធំៗផ្តល់ទៅឱ្យក្រុមហ៊ុន ដោយយកដីដែលអ្នកភូមិជនបទប្រើប្រាស់ធ្វើកសិកម្ម រឺសំរាប់ប្រមែប្រមូលធនធានធម្មជាតិ ។ NGOs និងម្ចាស់ជំនួយ បានលើកឡើងជារឿយៗពីការព្រួយបារម្ភនេះ ។ នាពេលថ្មីៗ NGOs នៅកម្ពុជា បានរកឃើញថា បញ្ហាទាំងនេះមិនមែនមានតែនៅកម្ពុជាទេប៉ុន្តែមាននៅទូទាំងអាស៊ីអគ្នេយ៍ ។ ក្នុងកិច្ចប្រជុំនៅខេត្តក្រចេះ ស្តីពីផលប៉ះពាល់នៃចំការដំណាំ ពួក NGOs មកពីតំបន់នេះបានប្រកាសថា "ចំការដំណាំ បានកាត់បន្ថយជាខ្លាំងនូវចំនួនដីសំរាប់ឱ្យសហគមន៍ជនបទធ្វើផលិតកម្មកសិកម្ម ។ សម្បទានចំការដំណាំជាច្រើន បានអនុញ្ញាតឱ្យក្រុមហ៊ុនកាត់យកដីមានជីជាតិបំផុតពីភូមិនានា ទៅដាំដុះដំណាំតែមួយមុខ ។ រឿងនេះមានផលប៉ះពាល់អវិជ្ជមានធ្ងន់ធ្ងរដល់បរិស្ថាននៅមូលដ្ឋាន ដូចជា ការបាត់បង់ជីវចំរុះ ការថយចុះគុណភាពដី កំណើនភាពខ្សោះហួតហែង និងការបំពុលប្រភពទឹកក្នុងមូលដ្ឋាន" ។[2]

គំរូល្អជាងនេះនៃការអភិវឌ្ឍន៍ជនបទ គឺអាចជាការដាក់ទុកធនធានឱ្យស្ថិតក្រោមការគ្រប់គ្រងរបស់កសិករកម្ពុជា ។ បើសិនមានសន្តិសុខកម្មសិទ្ធិដីធ្លីនិងលទ្ធភាពទទួលបានព័ត៌មាននិងធនធាន កសិករតូចតាចអាចបង្កើនផលិតភាព និងកសាងជីវភាពល្អប្រសើរសំរាប់ក្រុមគ្រួសាររបស់ខ្លួនបាន ។ សន្តិសុខស្បៀង និងអាហារូបត្ថម្ភ អាចកែលំអឡើងតាមរយៈការគាំទ្រកសិកម្មចំរុះរួមមាន ស្រូវ ត្រី បន្លែ ដំណាំលើភ្លឺស្រែ ដើមឈើហូបផ្លែ ។ល។ NGOs បានជួយមតិឱ្យផ្តល់សេវាផ្សព្វផ្សាយបច្ចេកទេសកសិកម្មដល់កសិករតូចតាច និងការប្រើបច្ចេកទេសចំណាយអស់ធាតុចូលតិច ដើម្បីបង្កើនផលដំណាំ ។

ដូចគ្នាដែរ នៅតំបន់ទីក្រុងត្រូវមានតុល្យភាពកាន់តែប្រសើររវាងផលប្រយោជន៍នៃការអភិវឌ្ឍន៍ពាណិជ្ជកម្ម ហើយនិងតំរូវការរបស់អ្នកក្រ ។ គេតែងចាត់ទុកកន្លែងតាំងទីលំនៅអនាធិបតេយ្យថាខុសច្បាប់ និងអាក្រក់មើល ប៉ុន្តែវាផ្តល់ផ្ទះស្នាក់នៅតំលៃថោក ដែលរកមិនបានទេនៅកន្លែងត្រឹមត្រូវ ។ ពលកម្មនិងសេវាកម្មថោកៗ ផ្តល់ដោយអ្នករស់នៅកន្លែងទាំងនោះ គឺជាចំណែកមួយដ៏សំខាន់នៃសេដ្ឋកិច្ចនៅទីក្រុង ។ ជំនួសឱ្យការដេញពួកគេចេញ គួរខំប្រឹងប្រែងផ្តល់សេវាកម្ម និងកែលំអសិទ្ធិកាន់កាប់ដីរបស់សហគមន៍ទាំងនេះវិញ ។

តុល្យភាពរវាងតំរូវការនិងសិទ្ធិរបស់អ្នកក្រ ហើយនិងតំរូវការនៃពាណិជ្ជកម្មចាំបាច់ត្រូវតែមាននៅក្នុងករណីទាំងអស់នេះ ។ ការអនុវត្តន៍ក្របខ័ណ្ឌច្បាប់មួយយ៉ាងរឹងមាំ ត្រូវតែធ្វើឡើងដើម្បីបង្កើតតុល្យភាពនេះឡើងវិញ ។ ដូច្នេះការផ្តល់សម្បទានដីសេដ្ឋកិច្ច ត្រូវមានការចុះបញ្ជីដីរដ្ឋជាមុន និងត្រូវវាយតំលៃពីផលប៉ះពាល់ខាងសេដ្ឋកិច្ច និងសង្គមកិច្ច ។ ការប្តូរកន្លែងប្រជាជនរស់

នៅអាចធ្វើបាន ដោយមានសំណងសមស្រប ។ ទោះយ៉ាងនេះក្តី ខ្ញុំសូមផ្តល់មតិថា ការយល់ឃើញរបស់យើងពីរឿង "ការអភិវឌ្ឍន៍" ក៏គួរមានតុល្យភាពជាងនេះដែរ ។ ការអភិវឌ្ឍន៍មិនគួរវាស់វែងតែតាមរយៈកំណើនសេដ្ឋកិច្ច រឺចំនួនវិនិយោគិនចូលមកប្រទេសយើងនោះទេ ។ ការអភិវឌ្ឍន៍គឺកើតមានឡើងនៅពេលមនុស្សធម្មតា ជាពិសេសអ្នកក្រនិងជនងាយរងគ្រោះ មានការរីកចំរើនភ្លាមៗ និងឋិតថេរយូរអង្វែងក្នុងសុខមាលភាព និងសមត្ថភាពគ្រប់គ្រងអនាគតរបស់ខ្លួន ។

### កំណត់សំគាល់

១. សូមមើលការវាយតំលៃភាពក្រីក្រនៅកម្ពុជា របស់ធនាគារពិភពលោក ឆ្នាំ២០០៦ និងអង្កេតស្តីពីសុខភាពនិងប្រជាសាស្ត្រកម្ពុជា របស់រាជរដ្ឋាភិបាលឆ្នាំ២០០៥

២. របាយការណ៍របស់សន្និសីទទន្លេមេគង្គក្នុងតំបន់ស្តីពីចំការដំណាំ នៅខេត្តក្រចេះ (ខែវិច្ឆិកា ឆ្នាំ២០០៦) ។

---

## តពីទំព័រ ៤ កម្ពុជា: ការពិនិត្យស្ថានភាពម៉ាក្រូសេដ្ឋកិច្ចពីឆ្នាំ២០០៧...

(D&D) ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (PFM) និងកំណែទំរង់រដ្ឋបាលសាធារណៈ (PAR) នឹងអាចជួយដោះស្រាយបញ្ហាប្រឈមបានមួយចំនួន ។ D&D កំពុងជឿនលឿនទៅមុខ ដោយមានមេរៀនល្អៗពីក្រុមប្រឹក្សាឃុំ ប៉ុន្តែនៅមានបញ្ហាប្រឈមចំពោះថ្នាក់ខេត្ត និងថ្នាក់ស្រុក ដូច្នេះត្រូវមានកំណែទំរង់វិសហមជ្ឈការតាមវិស័យពាក់ព័ន្ធទៀត ដើម្បីបំពេញបន្ថែមឱ្យកំណែទំរង់ D&D ។ កម្មវិធីកំណែទំរង់ PFM ក្នុងរយៈពេលពីរឆ្នាំចុងក្រោយបានចាប់ផ្តើមហុចលទ្ធផលគួរឱ្យកត់សំគាល់ហើយ ក្នុងការកែទំរង់ការគ្រប់គ្រងចំណូលចំណាយសាធារណៈ ។ វាបើកលទ្ធភាពជាច្រើនសំរាប់តំរង់ទិសចំណាយសាធារណៈឱ្យបានសក្តិសិទ្ធិនិងមានប្រសិទ្ធភាព ដើម្បីជួយកាត់បន្ថយភាពក្រីក្រ ។ PAR លូតលាស់ទៅមុខយឺតៗ ប៉ុន្តែត្រូវជួបនឹងបញ្ហាប្រឈមចំបងៗ ជាពិសេសក្នុងការកំណត់មុខងារច្បាស់លាស់សំរាប់ស្ថាប័នសាធារណៈ និងបុគ្គលិកស្ថាប័នទាំងនោះ ការបង្កើតគ្រឿងលើកទឹកចិត្តសំរាប់លទ្ធផលល្អ និងគណនេយ្យភាព និងការបង្កើតស្មារតីចង់កសាងស្នាដៃ និងវិជ្ជាជីវៈនិយមក្នុងចំណោមមន្ត្រីរាជការស៊ីវិល ។

### សេចក្តីសង្ខេប និងសន្និដ្ឋាន

មានសេចក្តីសន្និដ្ឋានចំបងៗបួន និងសំនួរស្តីពីគោលនយោបាយពាក់ព័ន្ធមួយចំនួន :

- កំណើនសេដ្ឋកិច្ចមានល្បឿនគួរឱ្យកត់សំគាល់ ប៉ុន្តែត្រូវមានយុទ្ធសាស្ត្ររយៈពេលមធ្យមនិងវែង ជាពិសេសសំរាប់ធ្វើចំរុះកម្មប្រភពកំណើន និងអភិវឌ្ឍវិស័យកសិកម្មឱ្យទៅជាក្បាលម៉ាស៊ីនទីបីនៃកំណើន ។ តើមានលទ្ធភាពអ្វីខ្លះសំរាប់ចែករំលែកវិបុលភាពឱ្យបានច្រើន? តើវិស័យឯកជន អាចធ្វើយ៉ាងណាដើម្បីរួមចំណែកកាន់តែមានប្រសិទ្ធភាពនៅក្នុងកំណើនសេដ្ឋកិច្ច និងមានឥទ្ធិពលដល់ការបង្កើតគោលនយោបាយ ?
- ការកាត់បន្ថយភាពក្រីក្របានសំរេចមួយកំរិតតូច ប៉ុន្តែវិសមភាព និងចលករភាពក្រីក្រដទៃទៀត (ដូចជា ភាពគ្មានដីធ្លី ឥរិយាបថគ្រោះថ្នាក់របស់បុរសៗ និងបញ្ហាប្រឈមចំពោះស្ត្រីជាមេគ្រួសារ) កំពុងផុសឡើង ។ តើកំណើនសេដ្ឋកិច្ច អាចជួយកាត់បន្ថយភាពក្រីក្រយ៉ាងដូចម្តេចបាន? តើគំនិតផ្តួចផ្តើម និងកម្មវិធីសាធារណៈអាចពង្រីកបន្ថែមយ៉ាងដូចម្តេច ដើម្បីឱ្យបានទៅដល់អ្នកក្រ និងជនងាយរងគ្រោះរួមទាំងស្ត្រីផង?
- ធនធានធម្មជាតិកាន់តែទទួលរងការខូចខាត និងការគំរាមកំហែងកាន់តែច្រើនឡើងៗ ដោយសារកង្វះការដាក់អនុវត្តន៍គោលនយោបាយ និងក្របខ័ណ្ឌច្បាប់ដែលមានស្រាប់ និងសមត្ថភាពទន់ខ្សោយរបស់តួអង្គនៅមូលដ្ឋាន ។ តើធនធានធម្មជាតិអាចគ្រប់គ្រង និងការពារយ៉ាងដូចម្តេច ដើម្បីជំរុញឱ្យអ្នកក្រមានឱកាសប្រើប្រាស់វាប្រកបដោយចីរភាព?
- កំណែទំរង់អភិបាលកិច្ច និងស្ថាប័ន នៅមិនទាន់រីកចំរើនគ្រប់គ្រាន់ទេ ដើម្បីជួយបង្កើនឱកាសយ៉ាងលឿនសំរាប់កំណើន និងការអភិវឌ្ឍន៍ ។ ការអនុមតិច្បាប់ប្រឆាំងអំពើពុករលួយ និងច្បាប់អង្គការ មានសារៈសំខាន់បំផុត គឺដូចគ្នានឹងការប្តេជ្ញាចិត្តខាងនយោបាយ និងការគាំទ្ររបស់សហគមន៍ ដើម្បីធ្វើកំណែទំរង់រដ្ឋាភិបាល ។ តើកំណែទំរង់ស្ថាប័នត្រូវអនុវត្តយ៉ាងដូចម្តេច ដើម្បីសំរេចគោលដៅរបស់រដ្ឋាភិបាល? តើប្រជាជនកម្ពុជា យល់ឃើញយ៉ាងណាពីឋានៈជាពលរដ្ឋរបស់ខ្លួន? តើយើងអាចកសាងមោទនភាពជាតិ និងការទទួលខុសត្រូវរបស់ប្រជាជនស៊ីវិលយ៉ាងដូចម្តេច ដើម្បីជំរុញនិងរក្សាបានការចូលរួមរបស់ប្រជាជន?
- ចក្ខុវិស័យវិទ្យាស្ថាន CDRI សំរាប់កម្ពុជាគឺ : (១) កំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព និងការចែករំលែកប្រកបដោយសមធម៌ នូវផលនៃកំណើន (២) ការសំរេចលក្ខខណ្ឌ MDG ក្នុងការកាត់បន្ថយភាពក្រីក្រឱ្យបានពាក់កណ្តាលនៅឆ្នាំ២០១៥ (៣) ការប្រើប្រាស់មានចីរភាពនូវការគ្រប់គ្រងដី និងធនធានធម្មជាតិ (៤) ការធ្វើសមាហរណកម្មទៅក្នុងប្រព័ន្ធពាណិជ្ជកម្ម និងអភិបាលកិច្ច ក្នុងតំបន់/អន្តរជាតិ និង (៥) ស្ថាប័នអភិបាលកិច្ចខ្លាំងក្លា និងមានប្រសិទ្ធភាពដែលឆ្លើយតបនឹងតំរូវការរបស់ប្រជាជន ។ នៅវិទ្យាស្ថាន CDRI យើងជឿជាក់ថា មធ្យោបាយដើម្បីសំរេចបាននូវចក្ខុវិស័យនេះ គឺត្រូវមាន រដ្ឋាភិបាល វិស័យឯកជន សង្គមស៊ីវិល និងដៃគូអភិវឌ្ឍន៍ធ្វើការរួមគ្នាដើម្បីអនាគតប្រទេសកម្ពុជា ។

### ឯកសារយោង


Eng Netra (2007), "CDRI's Vision for Cambodia's Development", Speech at the CDRI/ANZ Royal 2007 Cambodia Outlook Conference, February 23

Hang Chuon Naron (2007), "Macroeconomic Performance 2006–2015", Presentation at the CDRI/ANZ Royal 2007 Cambodia Outlook Conference, February 23

Nelmes, John (2007), "Cambodia: Macroeconomic Developments", Presentation at the CDRI/ANZ Royal 2007 Cambodia Outlook Conference, February 23

# តាមដានសេដ្ឋកិច្ច - ស្ថានភាពក្រៅប្រទេស

## កំណើនសេដ្ឋកិច្ចពិភពលោក

នៅត្រីមាសទី៤ ២០០៦ ផសស ពិត របស់ US កើនតាមអត្រាប្រចាំឆ្នាំ ២,៥% ធៀបនឹង ២,០% នៅត្រីមាសទី៣ ។ អត្រានេះឆ្លុះបញ្ចាំងជាសំខាន់ពីកំនើនចំណាយរបស់អ្នកប្រើប្រាស់ ការនាំចេញ ចំណាយរដ្ឋាភិបាល និងការធ្លាក់ចុះការនាំចូល ។

ផសស ពិត នៅតំបន់អឺរ៉ូ នៅត្រីមាសទី៤ ឆ្នាំ២០០៦ កើន ៣,៣% ខ្ពស់ជាងត្រីមាសដូចគ្នាឆ្នាំមុន និងកើន ០,៩% ធៀបនឹងត្រីមាសមុន ។ ផសស ពិត របស់ជប៉ុន កើន ២,៣% ធៀបនឹងមួយឆ្នាំមុន និង ១,២% ធៀបនឹងត្រីមាសមុន ។

នៅត្រីមាសទី៤ ឆ្នាំ២០០៦ សេដ្ឋកិច្ចចិននៅរក្សាកំណើនយ៉ាងខ្ពស់តាមអត្រាប្រចាំឆ្នាំ ១០,៧% ។ វិស័យឧស្សាហកម្មបន្តកើនឡើង (១២,៥%) លឿនជាងវិស័យសេវាកម្ម (១០,៣%) និងវិស័យកសិកម្ម (៥,០%) រីឯវិនិយោគ និងការនាំចេញនៅតែជាកត្តាជំរុញដ៏សំខាន់នៃកំណើនសេដ្ឋកិច្ចនេះ ។

ផសស ពិត នៅកូរ៉េខាងត្បូង នៅត្រីមាសទី៤ កើន ៥,០% ធៀបនឹងមួយឆ្នាំមុន និងកើន ០,៨% ធៀបនឹងត្រីមាសមុន ។ នៅត្រីមាសទី៤ ផសស ពិត របស់តៃវ៉ាន់ និងហុងកុង កើន ៤,០% និង ៧,០% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន ។

នៅត្រីមាសទី៤ សេដ្ឋកិច្ចម៉ាឡេស៊ី កើន ៥,៧% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន ។ ឧស្សាហកម្មផលិត និងសេវាកម្ម កើន ៤,៣% និង ៧,០% រីឯវិស័យកសិកម្ម កើន ៦,៥% ។ ចំណាយប្រើប្រាស់ចុងក្រោយ និងការនាំចេញថយកំណើនមកត្រឹម ៦,៧% និង ១០,៥% ធៀបនឹងមួយឆ្នាំមុន ។

សេដ្ឋកិច្ចសិង្ហបុរី នៅត្រីមាសទី៤ កើន ៧,០% ធៀបនឹងត្រីមាសដូចគ្នា ២០០៥ ។ ឧស្សាហកម្មផលិត កើន ៨,០% រីឯវិស័យសេវាកម្មកើន ៧,៧% ។

នៅត្រីមាសទី៤ ផសស ពិត នៅថៃ កើន ៤,៧% ធៀបនឹងត្រីមាសដូចគ្នា ឆ្នាំ២០០៥ ។ វិស័យកសិកម្មកើន ០,៩% រីតិចជាងត្រីមាសមុន (៤,៧%) ដោយសារការធ្លាក់ចុះផលិតកម្មដំណាំ សត្វចិញ្ចឹម និងការនេសាទ ។ វិស័យមិនមែនកសិកម្ម កើន ៤,៦% ធៀបនឹងមួយឆ្នាំមុន គឺតិចជាងកំណើន ៤,៧% នៅត្រីមាសមុន ។

## អតិផរណាក្នុងពិភពលោក និងអត្រាប្តូរប្រាក់នៅទីផ្សារអន្តរជាតិ

នៅត្រីមាសទី៤ ២០០៦ ថ្លៃទំនិញប្រើប្រាស់នៅ US ថយអត្រាកំនើនប្រចាំឆ្នាំមកត្រឹម ១,៩% ធៀបនឹងកំនើន ៣,៣% នៅត្រីមាសទី៣ ដោយសារប្រេងឆៅ និងថាមពលផ្សេងៗទាក់ទងនឹងប្រេងបានធ្លាក់ថ្លៃ ។ នៅតំបន់អឺរ៉ូ អតិផរណាមានអត្រា ១,៨% រីទាបបន្តិចជាងកំរិតអតិបរមា ២% កំណត់ដោយធនាគារកណ្តាលអឺរ៉ុប (European Central Bank: ECB) ។ ថ្លៃប្រេងធ្លាក់ចុះ គឺជាកត្តាចំបងនៃការថយចុះអត្រាអតិផរណានៅតំបន់អឺរ៉ូ ។ នៅជប៉ុន ថ្លៃទំនិញប្រើប្រាស់កើន ០,៣% ក្នុងរយៈមួយឆ្នាំដល់ត្រីមាសទី៤ ធៀបនឹង ០,៦% នៅត្រីមាសមុន ។ ទោះបីក្នុងរយៈមួយឆ្នាំនេះថ្លៃទំនិញប្រើប្រាស់កើនឡើងក្តី ប៉ុន្តែវាសឹងគ្មានភាពប្រែប្រួលទេ បើសិនគេមិនរាប់បញ្ចូលផលិតផលប្រេង និងកត្តាពិសេសៗឯទៀត ។

នៅទីផ្សារប្តូរប្រាក់អន្តរជាតិ ដុល្លារUS បានវិវត្តចំរុះទល់នឹងរូបិយវត្ថុចំបងៗ នៅត្រីមាសទី៤ ឆ្នាំ២០០៦ ។ ទល់នឹងប្រាក់យ៉េនជប៉ុន ដុល្លារUS ប្តូរបាន ១១៧,៨យ៉េន/ដុល្លារUS រីឡើងថ្លៃ បើធៀបនឹងអត្រា ១១៦,៣យ៉េន/ដុល្លារUS ក្នុងត្រីមាសទី៣ ។ ទល់នឹងប្រាក់អឺរ៉ូ វាប្តូរបាន ០,៧៨អឺរ៉ូ/ដុល្លារUS គឺស្មើនឹងអត្រានៅត្រីមាសមុន ។ ទល់នឹងប្រាក់វ៉ុនកូរ៉េខាងត្បូង និងប្រាក់យ៉ុនចិន ដុល្លារUS ធ្លាក់ថ្លៃមកត្រឹម ៩៣៨វ៉ុន/ដុល្លារUS និង ៧,៨៦យ៉ុន/ដុល្លារUS ធៀបនឹង ៩៥៥វ៉ុន/ដុល្លារUS និង ៧,៩៧យ៉ុន/ដុល្លារUS នៅត្រីមាសមុន ។ ការធ្លាក់ថ្លៃដុល្លារUS ជាប់ទាក់ទិននឹងប្រតិកម្មទីផ្សារចំពោះស្ថានភាពជាក់ស្តែង នៃការថយចុះសកម្មភាពសេដ្ឋកិច្ចនៅUS ខណៈដែលសេដ្ឋកិច្ចធំៗ (លើកលែងជប៉ុន) និងប្រទេសមួយចំនួននៅអាស៊ីអគ្នេយ៍បន្តមានកំណើនសេដ្ឋកិច្ចយ៉ាងខ្លាំង ។

## ថ្លៃទំនិញប្រើប្រាស់នៅទីផ្សារពិភពលោក

នៅត្រីមាសទី៤ ពោត ប្រេងឆា និងសណ្តែកសៀងឡើងថ្លៃ រីឯអង្ករ ប្រេងឆៅ សាំង និងម៉ាស៊ូតធ្លាក់ថ្លៃ ។ ប្រេងឆាលក់ថ្លៃ ៤៩៤,៩២ដុល្លារUS/តោន (ឡើងថ្លៃពី ៤៤៦,៨៥ដុល្លារUS/តោន) រីឯពោត និងសណ្តែកសៀងលក់ថ្លៃ ១៤០,១៨ដុល្លារUS/តោន និង ២៧៩,១០ដុល្លារUS/តោន ។ នៅទីផ្សារបាងកក អង្ករថៃ ១០០%B ធុនលេខ២ លក់ថ្លៃ ២៧៩,១០ដុល្លារUS/តោន គឺទាបជាងថ្លៃ ២៨៩,៩១ដុល្លារUS/តោន នៅត្រីមាសទី៣ ។ នៅត្រីមាសទី៤ ប្រេងឆៅធ្លាក់ថ្លៃ ១៦% ធៀបនឹងត្រីមាសមុន មកត្រឹម ៥៦,៣៩ដុល្លារUS/ធុង ។ សាំង និងម៉ាស៊ូតធ្លាក់ថ្លៃ ២២% និង ១៧% ធៀបនឹងត្រីមាសមុន ដោយលក់ថ្លៃ ៤១,០២សេន/លីត្រ និង ៤៦,១១សេន/លីត្រ នៅត្រីមាសទី៤ ឆ្នាំ២០០៦ ។

*រៀបរៀងដោយ ហ៊ីង វុត្ថា និង ភីម រុនស៊ីណារិទ្ធិ*

**តារាង១. កំណើន ផសស ពិត នៃដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០១-២០០៦ (កំណើនជាភាគរយធៀបនឹងឆ្នាំមុន)**

| | 2001 | 2002 | 2003 | 2004 | 2005 | 2006 | | | | 2005 |
|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q4 | Q1 | Q2 | Q3 | Q4 | |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | |
| កម្ពុជា | 6.7 | 4.8 | 7 | 7.7 | - | - | - | - | - | 13.4 |
| ឥណ្ឌូនេស៊ី | 3.8 | 3.8 | 4.9 | 5.1 | 4.9 | 4.6 | 5.2 | 5.5 | 6.1 | 5.6 |
| ម៉ាឡេស៊ី | 0.5 | 5.6 | 5.4 | 7 | 5.2 | 5.5 | 5.9 | 5.8 | 5.7 | 5.2 |
| សិង្ហបុរី | -2.3 | 2.6 | 1.4 | 8.5 | 7.7 | 10.7 | 8.0 | 7.1 | 7.0 | 5.7 |
| ថៃ | 1.9 | 6.1 | 6.9 | 6 | 4.7 | 6.0 | 4.9 | 4.7 | 4.2 | 4.5 |
| វៀតណាម | 6.0 | 6.7 | 7 | 7.5 | - | - | - | - | - | 8.4 |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | |
| ចិន | 7.5 | 8.1 | 9.9 | 9.5 | 9.9 | 10.9 | 11.3 | 10.4 | 10.7 | 9.6 |
| ហុងកុង | 0.5 | 5.0 | 3.2 | 8.3 | 7.6 | 8.2 | 5.2 | 6.8 | 7.0 | 6.5 |
| កូរ៉េខាងត្បូង | 3.0 | 6.1 | 3 | 4.7 | 5.2 | 6.1 | 5.3 | 4.8 | 5.0 | 4.7 |
| តៃវ៉ាន់ | -2.2 | 4.2 | 3.1 | 5.7 | 6.0 | 4.9 | 4.6 | 5.0 | 4.02 | - |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | |
| អឺរ៉ូ-១២ | 1.4 | 0.7 | 0.5 | 1.8 | 1.8 | 2.0 | 2.4 | 2.6 | 3.3 | 1.5 |
| ជប៉ុន | 0.4 | 0.4 | 2.6 | 3.4 | 4.5 | 3.0 | 2.2 | 2.7 | 2.3 | 2.5 |
| សហរដ្ឋអាមេរិក | 1.2 | 2.4 | 3.1 | 4.4 | 1.1 | 5.6 | 2.6 | 2.2 | 2.5 | 3.0 |

*Sources: Economist, countries' national statistics offices and central banks and ADB's Asia Regional Information Centre*